អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីជូនដំណឹងដល់អ្នកសារព័ត៌មាន
# កម្មវិធីផ្តល់ព័ត៌មានបឋមដល់អ្នកសារព័ត៌មាន អំពីការអានបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទក្នុងសំណុំរឿង ០០២

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សូមអញ្ជើញតំណាងសារព័ត៌មានជាតិ និងអន្តរជាតិចូលរួមក្នុងកម្មវិធីផ្តល់ព័ត៌មានបឋមដល់អ្នកសារព័ត៌មាន អំពីការអានបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និងសវនាការលើអង្គសេចក្តី នៃសំណុំរឿង ០០២ ដែលនឹងប្រព្រឹត្តទៅនៅសណ្ឋាគារ **សាន់វ៉េ** នៅថ្ងៃអាទិត្យ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១១ ចាប់ពីម៉ោង ៣:០០ ដល់ម៉ោង ៤:៣០ រសៀល។

កម្មវិធីផ្តល់ព័ត៌មានបឋម មានបំណងផ្តល់ព័ត៌មានអំពី អ.វ.ត.ក និងសំណុំរឿងដ៏សំខាន់បំផុតប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហមបួនរូបដែលនៅរស់រានមានជីវិត។ ក្នុងអំឡុងពេលនេះ នឹងមានការជូនដំណឹងអំពីសេវាបន្ថែមសម្រាប់អ្នកសារព័ត៌មាន ដែលផ្តល់ជូនដោយ អ.វ.ត.ក នៅក្នុងអំឡុងពេលសវនាការ ហើយក៏នឹងមានការចែកប័ណ្ណព័ត៌មានដល់អ្នកសារព័ត៌មានដែលបានដាក់ពាក្យសុំផងដែរ។

ការផ្តល់ព័ត៌មាននេះនឹងប្រព្រឹត្តទៅជាភាសាអង់គ្លេស ក៏ប៉ុន្តែបន្ទាប់ពីកម្មវិធីបានបញ្ចប់ អ្នកសារព័ត៌មានអាច សួរព័ត៌មានបន្ថែមជាភាសាខ្មែរ បារាំង និងភាសាជប៉ុនពីមន្ត្រីសាលាកិច្ចការសាធារណៈដែលមានវត្តមាន នៅទីនោះ។

**កាលវិភាគ:**

| ពេលវេលា | កម្មវិធី |
|---|---|
| ២:៤៥ - ៣:០០ | ចុះឈ្មោះ |
| ៣:០០ - ៣:០៥ | កិច្ចស្វាគមន៍អ្នកសារព័ត៌មាន<br>**ដោយលោក ឌីម សុវណ្ណារុំ មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក** |

| | |
|---|---|
| ៣:០៥ - ៣:៣០ | ការជម្រាបជូនអំពីការអានបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និងការចាប់ផ្តើមនៃសវនាការលើអង្គសេចក្តី នៃសំណុំរឿង ០០២<br>**ដោយលោក ឡាស អូលសិន មន្ត្រីទំនាក់ទំនងផ្នែកច្បាប់** |
| ៣:៣០ - ៤:២៥ | កម្មវិធីសំណួរនិងចម្លើយ<br>**ឆ្លើយសំណួរដោយមន្ត្រីកិច្ចការសាធារណៈទាំង៥រូប** |
| ៤:២៥ - ៤: ៣០ | ការជូនដំណឹងអំពីសេវាបន្ថែមដែលផ្តល់ជូនអ្នកសារព័ត៌មាននៅក្នុងអំឡុងពេលសវនាការ |

**មន្ត្រីកិច្ចការសាធារណៈដែលនឹងមានវត្តមានក្នុងកម្មវិធី៖**

លោក ឌឹម សុវណ្ណារុំ មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ

លោក ឡាស អូលសិន មន្ត្រីទំនាក់ទំនងផ្នែកច្បាប់

លោក នេត្រ ភក្ត្រា អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម

លោក ហ៊ុយ វណ្ណៈ មន្ត្រីកិច្ចការសាធារណៈ

លោកស្រី យូកូ ម៉ៃដា មន្ត្រីកិច្ចការសាធារណៈ

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:

លោក **នេត្រ ភក្ត្រា**

មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម

ទូរស័ព្ទដៃ៖ +៨៥៥(០)១២ ៤៨៣ ២៨៣

សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh